ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២៥៤ ប្រក. កសក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ឧបសម្ព័ន្ធបន្ថែម នៅក្នុងប្រកាសលេខ២០៨ ប្រក.កសក ស្តីពីនីតិវិធី និងការតម្រូវបមាណីយ សម្រាប់ការចុះបញ្ជីបសុឱសថ និងប្រកាសលេខ៤១៤ ប្រក.កសក ស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh Cambodia
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ២០៨ ប្រក.កសក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ
- បានឃើញប្រកាសលេខ៤១៤ ប្រក.កសក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ
- បានឃើញប្រកាសលេខ៣៨៤ ប្រក.កសក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាលដែលធ្វើពាណិជ្ជកម្ម និងធ្វើការលាយផ្សំ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ឧបសម្ព័ន្ធបន្ថែមទៅក្នុងប្រកាសលេខ២០៨ ប្រក.កសក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ និងប្រកាសលេខ៤១៤ ប្រក.កសក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២ .-**

គំរូទម្រង់ដែលកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះមានដូចខាងក្រោម៖

១- ទម្រង់០១ (ឋ) ៖ សេចក្តីអះអាងស្តីពីការទទួលខុសត្រូវលើបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការនាំចេញ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនសម្រាប់ការធ្វើពាណិជ្ជកម្ម។

២- ទម្រង់០២ (ឋ) ៖ សេចក្តីអះអាងស្តីពីការទទួលខុសត្រូវលើបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការដឹកជញ្ជូនសម្រាប់ការប្រើប្រាស់ផ្ទាល់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ២៥៤ ប្រក.កសក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

"ការដាក់ឱ្យប្រើប្រាស់ឧបសម្ព័ន្ធបន្ថែមទៅក្នុងប្រកាសលេខ២០៨ ប្រក.កសក
ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្ដីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ
និងប្រកាសលេខ៤១៤ ប្រក.កសក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និង
បទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី
ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ"

| ទម្រង់ | ឈ្មោះទម្រង់ | ចំនួនទំព័រ |
|---|---|---|
| ០១ (ប) | សេចក្ដីអះអាងស្ដីពីការទទួលខុសត្រូវលើបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការនាំចេញ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនសម្រាប់ការធ្វើពាណិជ្ជកម្ម | ២ |
| ០២ (ប) | សេចក្ដីអះអាងស្ដីពីការទទួលខុសត្រូវលើបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការដឹកជញ្ជូនសម្រាប់ការប្រើប្រាស់ផ្ទាល់ | ២ |

ទម្រង់០១ (ខ)

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្ដីអះអាង
## ស្ដីពី
## ការទទួលខុសត្រូវលើបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការនាំចេញ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និង ការដឹកជញ្ជូនសម្រាប់ការធ្វើពាណិជ្ជកម្ម

ដើម្បីជានាដល់ការគោរព និងអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដូចខាងក្រោម៖

- ច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន
- ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- គោលការណ៍អនុញ្ញាតបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការនាំចេញ ការផលិត ការលាយផ្សំ និងការវេចខ្ចប់ជាថ្មី លេខ............. ចុះថ្ងៃទី........ខែ..........ឆ្នាំ២០..........របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ហេតុដូច្នេះ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................... ភេទ................ អាយុ.......... ឆ្នាំ ជនជាតិ.................. សញ្ជាតិ.................. មុខរបរ/តួនាទី.................................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.............. ផ្លូវ.......... ភូមិ........................ ឃុំ/សង្កាត់........................ ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត.................................. អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ........................................ លេខទូរស័ព្ទ........................................ គេហទំព័ររបស់ក្រុមហ៊ុន សហគ្រាស..............................................................................។

## សូមធ្វើសេចក្ដីអះអាង ដោយធ្វើការសន្យាដូចខាងក្រោម៖

១-ធ្វើការចុះបញ្ជី ឬការនាំចូល ការនាំចេញ ការផលិត ការលាយផ្សំ និងការវេចខ្ចប់ជាថ្មីបសុឱសថ វត្ថុធាតុ-ជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលមានក្នុងគោលការណ៍អនុញ្ញាត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២-ធ្វើការចុះបញ្ជី ឬការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនតាមការកំណត់ដែលមានក្នុងលិខិតអនុញ្ញាត និងវិញ្ញាបនបត្ររបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ច។

៣-ធ្វើប្រតិវេទន៍ (កំណត់ត្រាសម្រាប់ប្រតិបត្តិការបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ) ជូនអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រាចំពោះបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលបានចុះបញ្ជិកា ឬនាំចូល មុនពេលធ្វើការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ឬនៅមុនពេលធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការដឹកជញ្ជូន។

៤-អនុវត្តតាមលក្ខខណ្ឌដែលភ្ជាប់កាតព្វកិច្ចក្នុងការកាន់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រទាំងឡាយដែលពាក់ព័ន្ធនឹងសត្វ និងផលិតផលសត្វ បសុឱសថ និងចំណីសត្វ ដូចមានចែងក្នុងមាត្រា ៨៨ នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

៥-មិនយកបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលបានចុះបញ្ជី ឬនាំចូល ទៅកែច្នៃប្រើប្រាស់ធ្វើជាសារធាតុញៀន គ្រឿងញៀន ឬសារធាតុបង្កគ្រោះថ្នាក់ដល់ សុខភាពមនុស្ស សុខភាពសត្វ បរិស្ថាន សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ។

៦-ទទួលទណ្ឌកម្ម និងជួសជុលការខូចខាតតាមច្បាប់ជាធរមាន ចំពោះការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សុខភាពសត្វ បរិស្ថាន ឬទ្រព្យសម្បត្តិសាធារណៈ។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................... សូមបញ្ជាក់ចំពោះសេចក្តីអះអាងដោយស្មោះត្រង់ និងពិតជាបានយល់ដឹងអំពីបទប្បញ្ញត្តិនៃច្បាប់ដែលបញ្ជាក់ជូនខាងលើ និងសូមធ្វើការទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ដើម្បីជាសក្ខីភាព សម្រាប់សេចក្តីអះអាង និងការសន្យាខាងលើ ខ្ញុំសូមផ្តិតស្នាមមេដៃនិងឈ្មោះ ឬហត្ថលេខា និងត្រាជាភស្តុតាង នៅទីកន្លែង និងកាលបរិច្ឆេទដូចខាងក្រោម៖

ថ្ងៃ.............................. ខែ............. ឆ្នាំ................ ព.ស. ២៥៦.....

..............................., ថ្ងៃទី......... ខែ.............. ឆ្នាំ២០....

ស្នាមមេដៃនិងឈ្មោះ ឬហត្ថលេខានិងត្រា

..................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់០២ (ខ)

# សេចក្ដីអះអាង
## ស្ដីពី
## ការទទួលខុសត្រូវលើបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការដឹកជញ្ជូនសម្រាប់ការប្រើប្រាស់ផ្ទាល់

ដើម្បីធានាដល់ការគោរព និងអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដូចខាងក្រោម៖

- ច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន
- ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- គោលការណ៍អនុញ្ញាតបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលស្នើសុំចុះបញ្ជី ឬធ្វើការនាំចូល ការផលិត ការលាយផ្សំ និងការវេចខ្ចប់ជាថ្មី លេខ............................ ចុះថ្ងៃទី........ខែ..........ឆ្នាំ២០..........របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ហេតុដូច្នេះ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ................................................ ភេទ.............. អាយុ......... ឆ្នាំ ជនជាតិ.................. សញ្ជាតិ................... មុខរបរ/តួនាទី................................................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.............. ផ្លូវ.......... ភូមិ........................ ឃុំ/សង្កាត់.......................... ក្រុង/ស្រុក/ខណ្ឌ......................... រាជធានី/ខេត្ត.................... អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ........................................ លេខទូរស័ព្ទ.................... គេហទំព័ររបស់ក្រុមហ៊ុន សហគ្រាស..............................................។

### សូមធ្វើសេចក្ដីអះអាង ដោយធ្វើការសន្យាដូចខាងក្រោម៖

១-ធ្វើការចុះបញ្ជី ឬការនាំចូល ការផលិត ការលាយផ្សំ និងការវេចខ្ចប់ជាថ្មីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលមានក្នុងគោលការណ៍អនុញ្ញាតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិញ្ញាបនបត្រចុះបញ្ជិកាដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

២-ធ្វើការចុះបញ្ជី ឬការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការដឹកជញ្ជូន តាមការកំណត់ដែលមានក្នុងលិខិតអនុញ្ញាត និងវិញ្ញាបនបត្ររបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលមានសមត្ថកិច្ច។

៣-ធ្វើប្រតិវេទន៍ (កំណត់ត្រាសម្រាប់ប្រតិបត្តិការបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ) ជូនអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រាចំពោះបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលបានចុះបញ្ជិកា ឬនាំចូល នាំចេញ មុនពេលធ្វើការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ឬនៅមុនពេលធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូន។

៤-អនុវត្តតាមលក្ខខណ្ឌដែលភ្ជាប់កាតព្វកិច្ចក្នុងការកាន់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រទាំងឡាយដែលពាក់ព័ន្ធនឹងសត្វ និងផលិតផលសត្វ បសុឱសថ និងចំណីសត្វ ដូចមានចែងក្នុងមាត្រា ៨៨ នៃច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ។

៥-មិនយកបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលបានចុះបញ្ជិកា ឬនាំចូល ទៅកែច្នៃប្រើប្រាស់ធ្វើជាសារធាតុញៀន គ្រឿងញៀន ឬសារធាតុបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សុខភាពសត្វ បរិស្ថាន សន្តិសុខជាតិ និងសណ្ដាប់ធ្នាប់សាធារណៈ។

៦-ទទួលទណ្ឌកម្ម និងជួសជុលការខូចខាតតាមច្បាប់ជាធរមាន ចំពោះការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សុខភាពសត្វ បរិស្ថាន ឬទ្រព្យសម្បត្តិសាធារណៈ។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................... សូមបញ្ជាក់ចំពោះសេចក្ដីអះអាងដោយស្មោះត្រង់ និងពិតជាបានយល់ដឹងអំពីបទប្បញ្ញត្តិនៃច្បាប់ដែលបញ្ជាក់ជូនខាងលើ និងសូមធ្វើការទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ដើម្បីជាសក្ខីភាព សម្រាប់សេចក្ដីអះអាង និងការសន្យាខាងលើ ខ្ញុំសូមផ្ដិតស្នាមមេដៃនិងឈ្មោះ ឬហត្ថលេខា និងត្រាជាភស្តុតាង នៅទីកន្លែង និងកាលបរិច្ឆេទដូចខាងក្រោម៖

ថ្ងៃ............................ ខែ............ ឆ្នាំ............... ព.ស. ២៥៦.....

.................................., ថ្ងៃទី......... ខែ............... ឆ្នាំ២០.....

ស្នាមមេដៃនិងឈ្មោះ ឬហត្ថលេខានិងត្រា

...............................................